01377757

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 17 / 01 / 2017
ម៉ោង (Time/Heure) : 14:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ១១ ខែ មករា ឆ្នាំ ២០១៧

## សវនាការលើភ័ស្តុតាង - ថ្ងៃ ៤៩៩

រៀបចំដោយ៖ លោកស្រី សែ កុលវុឌ្ឍី និង លោក Harshan ATHURELIYA

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម Claudia FENZ |
| ចៅក្រមបំរុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Harshan ATHURELIYA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ កញ្ញា សុង ឆវ័ន្ត, លោក Nicholas KOUMJIAN |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អារុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក ហុង គឹមសួន, លោកស្រី ស៊ិន សុវ៉ន |

| |
|---|
| ដើមបណ្តឹង/សាក្សី/អ្នកជំនាញ៖ |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ |
| ផ្សេងៗ៖ លោក ឡូញ ង៉ែត, លោកស្រី ពេជ ចរិយា, កញ្ញា Dhevy Sunantha SIVAPRAKASAM |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧ | ចាប់ផ្តើមម៉ោង៖ ០៩.០៤ | បញ្ចប់ម៉ោង៖ ១០.៤៣ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ០៩.៥៩ | បញ្ចប់ម៉ោង៖ ១០.២១ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០១ ម៉ោង និង ១៧ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៥ | ០៩.០៥ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា<br>អង្គជំនុំជម្រះ | ០៩.០៦ | ០៩.០៧ |
| សារណាផ្ទាល់មាត់ទាក់ទងនឹងអង្គហេតុចោទប្រកាន់ដែលនៅសេសសល់ក្នុងសំណុំរឿង០០២ | សហមេធាវីនាំមុខ<br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៩<br>០៩.៣១<br>០៩.៣៩<br>០៩.៤៥ | ០៩.៣០<br>០៩.៣៨<br>០៩.៤៥<br>០៩.៥៨ |
| សារណាផ្ទាល់មាត់ទាក់ទងនឹងបញ្ហាធនធានបុគ្គលិកផ្នែកការពារក្តី | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ | ១០.២៣<br>១០.២៩<br>១០.៣៥<br>១០.៣៦ | ១០.២៩<br>១០.៣៤<br>១០.៣៦<br>១០.៣៧ |
| សវនាការបិទបញ្ចប់ការដេញដោលពិនិត្យភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ | អង្គជំនុំជម្រះ | ១០.៣៧ | ១០.៤៣ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**សារណាផ្ទាល់មាត់របស់ភាគីទាក់ទងនឹងអង្គហេតុចោទប្រកាន់ដែលនៅសេសសល់ក្នុងសំណុំរឿង ០០២**

អង្គជំនុំជម្រះបានស្ដាប់សារណាផ្ទាល់មាត់របស់ សហមេធាវីនាំមុខ សហព្រះរាជអាជ្ញា មេធាវីការពារក្ដី នួន ជា និង មេធាវីការពារក្ដី ខៀវ សំផន ឆ្លើយតបទៅនឹងសំណើរបស់មេធាវីនាំមុខ សុំឱ្យធ្វើការបញ្ជាក់ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ (E439)។ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះនឹងយកមតិយោបល់របស់ភាគីទៅពិនិត្យពិចារណា ដើម្បីចេញសេចក្ដីសម្រេចលើបញ្ហានេះក្នុងពេលសមស្រប។

**សារណាផ្ទាល់មាត់របស់ភាគីទាក់ទងនឹងបញ្ហាធនធានបុគ្គលិកផ្នែកការពារក្ដី**

អង្គជំនុំជម្រះបានស្ដាប់សារណាផ្ទាល់មាត់របស់ មេធាវីការពារក្ដី នួន ជា និង មេធាវីការពារក្ដី ខៀវ សំផន សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខ ទៅនឹងសំណើសុំកាត់បន្ថយថវិកាផ្នែកការពារក្ដីដែលអាចមានផលប៉ះពាល់ ដល់ការងាររបស់ក្រុមមេធាវីការពារក្ដីមុនកាលបរិច្ឆេទនៃការដាក់សេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើភស្តុតាង និងការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើភស្តុតាង។ អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីថា អង្គជំនុំជម្រះនឹងយកមតិយោបល់របស់ភាគីទៅពិនិត្យពិចារណា និងពិភាក្សាជាមួយការិយាល័យរដ្ឋបាលដើម្បីដោះស្រាយទៅលើបញ្ហានេះ។

**សវនាការបិទបញ្ចប់ការដេញដោលពិនិត្យភស្តុតាងក្នុងសំណុំរឿង ០០២/០២**

អង្គជំនុំជម្រះបានជូនដំណឹងពីការបិទបញ្ចប់សវនាការដេញដោលពិនិត្យភស្តុតាងក្នុងសំណុំរឿង០០២/០២ នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី អង្គជំនុំជម្រះអាចនឹងបើកកិច្ចដំណើរការនីតិវិធីសវនាការឡើងវិញដើម្បីស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-946 តាមរយៈប្រព័ន្ធសោតទស្សន៍ ប្រសិនបើអង្គជំនុំជម្រះបានរៀបចំបានមិនឱ្យហួសពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧។

អង្គជំនុំជម្រះនឹងជូនដំណឹងទៅភាគីអំពីវឌ្ឍនភាពនៃបញ្ហានេះ។

អង្គជំនុំជម្រះបានរំលឹកដល់ភាគីថាពេលវេលាកំណត់ចុងក្រោយសម្រាប់ដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលនឹងត្រូវដាក់នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧ ហើយមិនអនុញ្ញាតឱ្យមានការឆ្លើយតបជាលាយលក្ខណ៍អក្សរទេ។ សហព្រះរាជអាជ្ញា ត្រូវបានអនុញ្ញាតឱ្យដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន មិនឱ្យលើសពី ៨០០ ទំព័រ, មេធាវីការពារក្តី ត្រូវបានអនុញ្ញាតត្រឹមតែ ៥៥០ ទំព័រ សម្រាប់ក្រុមនីមួយៗ និង សហមេធាវីនាំមុខ ត្រូវបានអនុញ្ញាតត្រឹមតែ ៥៥០ ទំព័រ សម្រាប់សេចក្តីសន្និដ្ឋានលើបញ្ហាទាំងអស់ រួមទាំងបញ្ហាសំណងផងដែរ។ អង្គជំនុំជម្រះក៏បានរំលឹកបន្ថែមទៀតដល់សហមេធាវីនាំមុខតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីថា កាលបរិច្ឆេទចុងក្រោយសម្រាប់ការទាមទារសំណងចុងក្រោយត្រូវបានកំណត់ពេលឱ្យដាក់ត្រឹមថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៧។

អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា សេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោលនឹងត្រូវចាប់ផ្តើមធ្វើនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៧។ អង្គជំនុំជម្រះបានអនុញ្ញាតឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល ១ថ្ងៃ សហព្រះរាជអាជ្ញាមានរយៈពេល ៣ថ្ងៃ និងសហមេធាវីការពារក្តីមួយក្រុមៗមានរយៈពេល ២ថ្ងៃ។ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះផ្តល់រយៈពេល ១ថ្ងៃ សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានឆ្លើយតប និងរយៈពេល ៤ម៉ោង សម្រាប់ការធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយរបស់ជនជាប់ចោទទាំងពីររូប ប្រសិនបើជនជាប់ចោទជ្រើសរើសអនុវត្តសិទ្ធិនេះ។

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E439 | | 01326293 – 01326299/ 01324957 – 01324962/ / | Civil Party Lead Co-Lawyers' Request for clarification relating to remaining charges in Case 002 | P | / | / | / |
| E439/1 | | 01328319 – 01328326/ / 01328312 – 01328316 | Observations de la Défense de M. KHIEU Samphân en réponse à la demande de clarification des Parties civiles concernant les poursuites restantes du dossier 002 | P | / | / | / |
| E439/2 | | 01328336 – | Nuon Chea's response to civil party lead co-lawyers' request | P | / | / | / |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 01328349/<br>01327865<br>-<br>01327874/<br>/ | for clarification relating to the remaining charges in case 002 | | | | |
| E439/3 | | 01328350<br>-<br>01328358/<br>01328329<br>-<br>01328335/<br>/ | Co-prosecutors' response to civil party lead co-lawyers' request for clarification relating to the remaining charges in case 002 | P | / | / | / |
| E439/4 | | 01329705<br>-<br>01329709/<br>01329701<br>-<br>01329704/<br>/ | Civil Party Lead Co-Lawyers' reply to Nuon Chea's response to Request for clarification relating to remaining charges in Case 002 | P | / | / | / |
| E301/9/1/1/3 | | 01003086<br>-<br>01003159/<br>01003043<br>-<br>01003085/<br>01033816<br>-<br>01033875 | Decision on KHIEU Samphan's immediate appeal against the Trial Chamber's decision on additional severance of Case 002 and scope of Case 002/02 | P | 01003136<br>-<br>01003137;<br>01003072<br>-<br>01003073;<br>01033856 | 01003157<br>-<br>01003158;<br>01003084;<br>01033873<br>-<br>01033874 | 01003145;<br>01003077;<br>01033863 |
| E275/2/1/1 | | 00943772<br>-<br>00943819/<br>00950531<br>-<br>00950560/<br>00942454<br>-<br>00942483 | Urgent request by the defence team of Mr. KHIEU Samphan for an immediate stay of proceedings | P | 00943774;<br>00943776 | 00950532;<br>00950533 | 00942455;<br>00942456 |

<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៦)
- បិទបញ្ចប់សវនាការដេញដោលលើភ័ស្តុតាងសំណុំរឿង ០០២/០២ ប៉ុន្តែអាចនឹងបើកកិច្ចដំណើរការនីតិវិធីសវនាការឡើងវិញដើម្បីស្ដាប់សក្ខីកម្មសាក្សី 2-TCW-946 មិនឱ្យហួសពីថ្ងៃទី ៣១

ខែ មករា ឆ្នាំ ២០១៧។ (១០.៣៩)

- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញចុះ។ (១០.៤៣)

| កាលវេលាសវនាការបន្ត |
| --- |
| សវនាការស្ដាប់សេចក្ដីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោល នឹងត្រូវចាប់ផ្ដើមធ្វើនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៧ ចាប់ផ្ដើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧

ក្រឡាបញ្ជី ក្រឡាបញ្ជី

លោកស្រី សែ គុនធា លោក Harshan ATHURELIYA